# មេរៀនទី ១០: ព្រះយេស៊ូវត្រូវគេបដិសេធនៅស្រុកកំណើតរបស់ទ្រង់

## លូកា ៤:២២-៣០

**គោលបំណង៖** ព្រះយេស៊ូវយាងមកដើម្បីមនុស្សគ្រប់គ្នា។

**ខគម្ពីរចងចាំ៖ យ៉ូហាន ៣:១៧** *"ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជំរះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះដោយសារទ្រង់វិញ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

នៅពេលដែលអ្នកអានគម្ពីរ **លូកា ៤:២២-៣០**ឡើងវិញ សូមគិតថាអ្នកជាជនជាតិយូដានៅក្នុងស្រុកណាសារ៉ែត។ ពិនិត្យមើលជីវិតរបស់អ្នក ហើយគិតអំពីគ្រាដែលអ្នកអាចនឹងមានអារម្មណ៍ថា មនុស្សមិនសមនឹងទទួលបានព្រះគុណរបស់ព្រះទេ។ ហេតុអ្វីបានជាពេលខ្លះយើងជឿថា មានតែមនុស្សប្រភេទបែបនេះ ឬបែបនោះដែលអាចទទួលបានព្រះគុណរបស់ព្រះ? មនុស្សគ្រប់រូបអាចទទួលបានព្រះគុណរបស់ព្រះ។ សូមអធិស្ឋានសម្រាប់កុមារ ដើម្បីពួកគេអាចទទួលបទពិសោធន៍ពីព្រះតាមរយៈមេរៀនថ្ងៃនេះ។

**ចំរៀង៖** ១. ព្រះយេស៊ូវគឺជាព្រះអម្ចាស់ ២. ព្រះអម្ចាស់យើងល្អណាស់ ៣. តើអ្នកណាជាម្ចាស់នៃខ្ញុំ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «បៃតង ឬក្រហម»**

**សម្ភារៈដែលត្រូវការ៖** ក្រដាសពណ៌បៃតង និងក្រដាសពណ៌ក្រហម



១. នៅពេលកុមារចូលមកក្នុងថ្នាក់រៀន គ្រូចែកក្រដាពណ៌បៃតងទៅក្រុមមួយ និងចែកក្រដាសពណ៌ក្រហមទៅក្រុមមួយទៀត (ពាក់កណ្តាលម្នាក់)។

២. ប្រាប់កុមារៗថា ថ្ងៃនេះអ្នកមានរឿងដ៏ពិសេសមួយចង់ប្រាប់ពួកគេ ប៉ុន្តែមានតែក្រុមកុមារដែលមានក្រដាសពណ៌បៃតងតែប៉ុណ្ណោះអាចស្តាប់រឿងនេះបាន។

៣. គ្រូហៅកុមារដែលមានក្រដាសពណ៌បៃតងមកជុំគ្នានៅជុំវិញខ្លួន ហើយឲ្យកុមារដែលមានក្រដាសក្រហមទៅនៅក្រៅថ្នាក់។

៤. នៅពេលដែលក្រុមទាំង២បានបំបែកគ្នាហើយ សូមសួរទៅកាន់កុមារក្នុងក្រុមបៃតងថា តើគេមានអារម្មណ៍បែបណា នៅពេលដែលពួកគេត្រូវបានជ្រើសរើសឲ្យស្តាប់រឿងដែលអ្នកគ្រូនឹងនិយាយនេះ (ខ្ញុំសប្បាយចិត្តដែលខ្ញុំអាចនៅក្នុងក្រុមពណ៌បៃតង ប៉ុន្តែខ្ញុំមានអារម្មណ៍អាណិតចំពោះក្រុមពណ៌ក្រហម)

៥. សូមសួរក្រុមពណ៌ក្រហមថាគេមានអារម្មណ៍បែបណា នៅពេលដែលពួកគេមិនត្រូវបានជ្រើសរើស (ខ្ញុំមានអារម្មណ៍មិនសប្បាយចិត្តទេ ខ្ញុំចង់នៅក្នុងក្រុមពណ៌បៃតង ខ្ញុំមិនយល់ទេថាហេតុអ្វីបានជាខ្ញុំមិនត្រូវបានគេជ្រើសរើស)

៦. សូមពន្យល់កុមារថា លោកីយ៍នេះគឺគេចូលចិត្តបែងចែកមនុស្ស ហើយចូលចិត្តទុកអ្នកដទៃទៀត នៅក្នុង

ក្រុមរបស់ពួកគេ។ ប៉ុន្តែព្រះយេស៊ូវមិនធ្វើបែបនេះទេ ព្រះអង្គមិនបែងចែកមនុស្សដោយផ្អែកទៅលើពណ៌សម្បុរ សំលៀកបំពាក់ស្អាត មុខស្អាត សង្ហា ឆ្លាត ឬល្ងង់ទេ។

៧. មិនថាប្អូនមានក្រដាសពណ៌បៃតង ឬពណ៌ក្រហមទេ ព្រះយេស៊ូវស្រលាញ់ប្អូនទាំងអស់គ្នា!

## ៤. ការណែនាំមេរៀន

តើអ្នកធ្លាប់ត្រូវបានគេបោះបង់ចោល ឬនៅតែម្នាក់ឯងដែរឬទេ? តើមានអារម្មណ៍យ៉ាងណាដែរនៅពេលដែលគេទុកអ្នកចោល ហើយអ្នកត្រូវនៅតែម្នាក់ឯង? មនុស្សគ្រប់រូបតែងតែធ្លាប់ជួបនូវរឿងមួយនេះ គឺត្រូវបានគេទុកចោលអាចថាមួយដង ឬច្រើនដងក៏មាន។ អារម្មណ៍ដែលត្រូវគេទុកចោល មិនមែនជារឿងលេងសើចនោះទេ។ វាអាចធ្វើឲ្យយើងមានអារម្មណ៍ភ័យខ្លាច យំ កើតទុក្ខ ឯកោ និងបាក់ទឹកចិត្ត។ ថ្ងៃនេះយើងនឹងនិយាយអំពីការពិតដែលថា ព្រះយេស៊ូវគឺសម្រាប់មនុស្សគ្រប់គ្នា។ ព្រះយេស៊ូវមិនដែលទុកនរណាម្នាក់ចោលឡើយ ព្រះអង្គយាងមកដើម្បីមនុស្សគ្រប់គ្នា។ មិនថាអ្នកមានរូបរាងបែបណា ឬអ្នកប្រព្រឹត្តិបែបណានោះទេ ព្រះយេស៊ូវស្រលាញ់អ្នក ហើយចង់ឲ្យអ្នកជាចំណែកមួយនៅក្នុងគ្រួសាររបស់ទ្រង់។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

ពេលខ្លះមនុស្សមួយចំនួនត្រូវបានអ្នកដទៃប្រព្រឹត្តយ៉ាងអាក្រក់ដាក់ពួកគេ ដោយសារតែអាយុ ឬពណ៌សម្បុររបស់ពួកគេ ឬក៏ដោយសារប្រទេសកំណើតរបស់ពួកគេជាដើម។ ពេលខ្លះមនុស្សពិបាកទទួលយកអ្នកដែលមានលក្ខណៈខុសពីគេបន្តិច។ ព្រះយេស៊ូវចង់ឱ្យយើងមានសេចក្តីស្រឡាញ់ និងទទួលយកមនុស្សគ្រប់គ្នា ទោះបីជាពួកគេមានលក្ខណៈខុសពីគ្នាក៏ដោយ។ ព្រះយេស៊ូស្រឡាញ់មនុស្សគ្រប់គ្នា ហើយព្រះអង្គចង់ឲ្យមនុស្សទាំងអស់ជឿលើទ្រង់ និងដើរតាមទ្រង់។ ព្រះយេស៊ូវយាងមកគឺដើម្បីមនុស្សគ្រប់គ្នា។

ព្រះគម្ពីរសញ្ញាចាស់ប្រាប់យើងថា ប្រជាជនអ៊ីស្រាអែល (ពួកគេត្រូវបានហៅថាជាជនជាតិយូដា) បានរង់ចាំក្នុងការយាងមករបស់ព្រះមេស្ស៊ីអស់រយៈពេលរាប់រយឆ្នាំមកហើយ។ នៅពេលដែលព្រះយេស៊ូវយាងមករស់នៅលើផែនដីមានជនជាតិយូដាជាច្រើនបានគិតថា ព្រះមេស្ស៊ីគឺយាងមកសម្រាប់តែជនជាតិអ៊ីស្រាអែលតែប៉ុណ្ណោះ។ ព្រះយេស៊ូវមានបន្ទូលប្រាប់ពួកគេថា ព្រះមេស្ស៊ីគឺយាងមកសម្រាប់មនុស្សគ្រប់គ្នានៅគ្រប់ប្រទេសទាំងអស់។ ព្រះអង្គក៏ជាព្រះមេស្ស៊ីសម្រាប់ប្រទេសកម្ពុជាយើងផងដែរ! ហើយមានមនុស្សជាច្រើននៅក្នុងប្រទេសអ៊ីស្រាអែលនៅតែមិនទាន់យល់ពីការនេះនៅឡើយ។

ថ្ងៃមួយ ព្រះយេស៊ូវយាងទៅសាលាប្រជុំ (ដូចព្រះវិហារ) ដើម្បីថ្វាយបង្គំព្រះជាម្ចាស់នៅឯស្រុកកំណើតរបស់ទ្រង់ឈ្មោះស្រុកណាសារ៉ែត។ ទ្រង់បានមានបន្ទូលប្រាប់មនុស្សនៅទីនោះថា ព្រះជាម្ចាស់បានចាត់ទ្រង់ឱ្យមកជួយដល់អស់អ្នកណាដែលជម្ងឺឲ្យបានជា ហើយអស់អ្នកដែលសោកសៅឲ្យឈប់កើតទុក្ខតទៅទៀត។ មិនតែប៉ុណ្ណោះ ព្រះយេស៊ូវមានព្រះបន្ទូលទៅកាន់ពួកគេថា ព្រះអង្គមិនមែនគ្រាន់តែជួយដល់ជនជាតិយូដាប៉ុណ្ណោះទេ ប៉ុន្តែគឺទ្រង់បានយាងមកសម្រាប់មនុស្សគ្រប់គ្នាក្នុងលោកីយ៍នេះទាំងមូល។

ការនេះបានធ្វើឲ្យជនជាតិយូដាខឹងជាខ្លាំង។ ពួកគេគិតថាព្រះយេស៊ូវគួរតែមកជួយដល់ជនជាតិអ៊ីស្រាអែលតែប៉ុណ្ណោះ។ ពួកគេមិនចង់ចែករំលែកព្រះយេស៊ូវជាមួយនឹងមនុស្សឯទៀតនៅក្នុងពិភពលោកនេះទេ។ ជនជាតិយូដានៅក្នុងសាលាប្រជុំខឹងខ្លាំងណាស់ ហើយពួកគេបានក្រោកដើរចេញពីកន្លែងដែលពួកគេកំពុងថ្វាយបង្គំ

ហើយបណ្តេញព្រះយេស៊ូវចេញពីទីក្រុង។ ពួកគេមានបំណងចង់សំលាប់ព្រះយេស៊ូវ ដោយបណ្តើរទ្រង់ទៅដល់ចំរេះ(ច្រាំងថ្ម)ដើម្បីច្រានទ្រង់ទំលាក់ចុះទៅក្រោម។ ប៉ុន្តែព្រះយេស៊ូវបានដើរកាត់ហ្វូងមនុស្ស ហើយបានបន្តដំណើររបស់ទ្រង់ទៅមុខទៀត។ ទោះបីជាជនជាតិយូដាខឹងនឹងព្រះអង្គខ្លាំងយ៉ាងណាក៏ដោយ ក៏ព្រះយេស៊ូវនៅតែដឹងថា ព្រះអង្គយាងមកគឺដើម្បីមនុស្សគ្រប់គ្នានៅលើលោកីយ៍នេះ! ហើយនេះគឺជាដំណឹងល្អសំរាប់យើងទាំងអស់គ្នា។

**៦. សំនួរពិភាក្សា**

១. តើជនជាតិយូដាគិតថាព្រះយេស៊ូវយាងមកសង្គ្រោះអ្នកណា? *សង្គ្រោះតែជនជាតិយូដាតែប៉ុណ្ណោះ*

២. តើព្រះយេស៊ូវមានបន្ទូលថាទ្រង់យាងមកសង្គ្រោះអ្នកណា? *មនុស្សគ្រប់គ្នានៅលើលោកីយ៍នេះ*

៣.តើលោកីយ៍នេះនឹងក្លាយទៅជាយ៉ាងណា ប្រសិនបើព្រះយេស៊ូវយាងមកសំរាប់តែមនុស្សមួយក្រុមនោះ? *លោកីយ៍នេះនឹងសំបូរទៅដោយអ្នកមិនជឿព្រះ ហើយក៏គ្មានអ្នកណាបានឮពីព្រះយេស៊ូវដែរ*

៤. តើអ្នកមានអារម្មណ៍ដូចម្តេច ពេលដែលដឹងថាព្រះយេស៊ូវយាងមកដើម្បីសង្គ្រោះមនុស្សគ្រប់គ្នារួមទាំងប្រជាជនកម្ពុជាដែរនោះ? *ទុកឲ្យកុមារជាអ្នកឆ្លើយ*

**៧. ល្បែងកំសាន្ត** «ព្រះយេស៊ូវយាងមកដើម្បីមនុស្សគ្រប់គ្នា»




១. បែងចែកកុមារជាក្រុមតូចៗ ដោយក្នុងមួយក្រុមមានគ្នាពី៤ ទៅ៥នាក់

២.សូមឲ្យកុមារនៅក្នុងក្រុមនីមួយៗរកវិធីសាស្រ្តបញ្ចុះបញ្ចូលមនុស្សឲ្យពួកគេជឿថាព្រះយេស៊ូវគឺយាងមកដើម្បីមនុស្សគ្រប់គ្នា។ បទបង្ហាញរបស់ពួកគេត្រូវតែ។បញ្ចុះបញ្ចូលមនុស្សឲ្យពួកគេជឿថាព្រះយេស៊ូវគឺយាងមកដើម្បីមនុស្សគ្រប់គ្នា។

៣. ក្រុមនីមួយៗមានពេលពី៥ទៅ១០នាទីដើម្បីរៀបចំនូវបទបង្ហាញរបស់ពួកគេ។

៤. ពេលដែលពួកគេបានរៀបចំរួចហើយ សូមឲ្យក្រុមនីមួយៗធ្វើបទបង្ហាញអំពីគំនិតរបស់ពួកគេ។

**៨. ខគម្ពីរចងចាំ** យ៉ូហាន ៣:១៧

**៩. ហត្ថកម្ម** ផាត់ពណ៌លើរូបភាព "ព្រះយេស៊ូវស្រឡាញ់យើងគ្រប់គ្នា"

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ព្រះយេស៊ូវស្រឡាញ់យើងគ្រប់គ្នា



**យ៉ូហាន ៣:១៧**“*ពីព្រោះព្រះទ្រង់មិនបានចាត់ព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងលោកីយ៍ ដើម្បីនឹងជំនុំជំរះលោកីយ៍នោះទេ គឺឲ្យលោកីយ៍បានសង្គ្រោះ ដោយសារទ្រង់វិញ។*”